# បទយកការណ៍៖ សមាជិកស្រ្តីថ្ងៃសុក្រ អ្នកស្រី សោម ចន្ធូ ស្លាប់ ខណៈបំណងចង់ឃើញស្វាមី

ចេញពីពន្ធនាគារមិនបានសម្រេច



ក្រុមស្ត្រីថ្ងៃសុក្រ ដែលសកម្មចេញមុខទាមទារឱ្យតុលាការដោះលែងស្វាមីរបស់ខ្លួន បានរម្លឹកពីការតស៊ូរបស់អ្នកស្រី **សោម ចន្ធូ** ដែលបានទទួលមរណភាពកាលពីពេលថ្មីៗនេះ ទាំងមិនទាន់សម្រេចបំណងរកយុត្តិធម៌ឱ្យស្វាមីដែលកំពុងជាប់ឃុំក្នុងពន្ធនាគារត្រពាំងផ្លុងបាននៅឡើយ។

អ្នកស្រី **សោម ចន្ធូ** វ័យ៥៣ឆ្នាំ គឺជាភរិយារបស់លោក **សុខ ចន្ថា** អតីតសមាជិកក្រុមប្រឹក្សាខេត្តព្រៃវែង មកពីគណបក្សសង្គ្រោះជាតិដែលតុលាការបានរំលាយ។ គាត់បានទទួលមរណភាព នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២ ដោយសារជំងឺលើសសម្ពាធឈាម និងទឹកនោមផ្អែមក្រោយពេលមកពីជួបសួរសុខទុក្ខស្វាមី នៅពន្ធនាគារត្រពាំងផ្លុង ខេត្តត្បូងឃ្មុំ បានប្រហែលមួយសប្ដាហ៍។

ស្របពេលដែលបាត់បង់ អ្នកស្រី **សោម ចន្ធូ** ជារៀងរហូតបែបនេះ សមាជិកស្ត្រីថ្ងៃសុក្រផ្សេងៗទៀត បានបង្ហាញក្ដីស្រណោះ និងរម្លឹកពីវីរៈភាពរបស់អ្នកស្រី **សោម ចន្ធូ** ដែលតែងតែចូលរួមសកម្មភាពលើកបដា និងស្រែកទាមទារកណ្ដាលរាជធានីភ្នំពេញឱ្យតុលាការដោះលែងស្វាមីរបស់ខ្លួន និងមន្ត្រីអតីតគណបក្សសង្គ្រោះជាតិដែលកំពុងជាប់ឃុំរៀងរាល់ថ្ងៃសុក្រ ស្ទើរមិនដែលអាក់ខានម្ដងណាឡើយ ទោះបីជាគាត់មានជំងឺប្រចាំកាយក្ដី។

សមាជិកស្ត្រីថ្ងៃសុក្រម្នាក់ គឺអ្នកស្រី **ព្រំ ចាន់ថា** វ័យ៥៥ឆ្នាំប្រាប់វីអូឌីថា អ្នកស្រី **សោម ចន្ធូ** ជាមនុស្សម្នាក់រួសរាយរាក់ទាក់ មិនតម្កើនខ្លួន ហើយស្លូតបូត។ អ្នកស្រីថា គាត់សឹងតែមិនអាចទទួលយកបានចំពោះមរណភាពរបស់អ្នកស្រី **សោម ចន្ធូ** ដោយថា ពេលវេលាហាក់បីដូចជាលឿនពេកចំពោះការស្លាប់នេះ។ អ្នកស្រីបន្តថា អ្នកស្រី **សោម ចន្ធូ** បានចូលរួមតវ៉ាជាមួយសមាជិកស្ត្រីថ្ងៃសុក្រផ្សេងទៀត ទាំងជីវភាពក្រីក្រលំបាក ដោយត្រូវរកចំណូលទ្រទ្រង់ជីវភាពគ្រួសារផង និងចេញមុខធ្វើសកម្មភាពដែលប្រឈមនឹងសុវត្ថិភាពផ្ទាល់ខ្លួនផង។

អ្នកស្រីបន្តថា៖ «*គាត់ព្យាយាមក្នុងការមកតវ៉ាណាស់អូន! គាត់ឆ្ងាយហើយ គាត់មកជិះម៉ូតូជូនណាទៅគ្រោះថ្នាក់ចរាចរណ៍ រលាត់ដៃជើងអីគាត់ថាមិនអីទេ គាត់នៅតែមកអ៊ីចឹង។ គាត់ព្យាយាមមែនទែន អាណិតគាត់ខ្លាំងណាស់ខ្ញុំនោះ និយាយតាមត្រង់បាត់បង់គាត់គឺខ្ញុំសោកស្ដាយមែនទែន*»។

អ្នកស្រីបានរម្លឹកថា កាលនៅមានជីវិត អ្នកស្រី **សោម ចន្ធូ** ធ្លាប់បាននិយាយពីគោលបំណងរបស់គាត់ដោយចង់ឃើញស្វាមីចេញពីមន្ទីរឃុំឃាំង វិលមកជួបជុំក្រុមគ្រួសារឡើងវិញ ប៉ុន្តែ ក្ដីស្រមៃនេះមិនទាន់បានសម្រេចផង អ្នកស្រី **សោម ចន្ធូ** បានស្លាប់មុនគោលបំណងបានសម្រេចទៅវិញ។

អ្នកស្រីបន្ថែមថា៖ «*អនាគតទៅមាន [ប្រជាធិបតេយ្យ] ពិត ឬក៏អាចមានប្រជាធិបតេយ្យ មានការផ្លាស់ប្ដូរក្នុងពេលឆាប់ៗ នេះគឺខ្ញុំនឹងសុំឱ្យ ធ្វើសំណាកគាត់ [រូបសំណាកអ្នកស្រី សោម ចន្ធូ] នឹងអាចមានការចងចាំដែលវីរៈភាពរបស់ពួកខ្ញុំធ្វើការតស៊ូដើម្បីប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជាទូទៅ*»។

**ក្រុមស្ត្រីថ្ងៃសុក្រ** ជាឈ្មោះផ្លូវការរបស់ ភរិយាមន្ត្រីគណបក្សសង្គ្រោះជាតិដែលតុលាការបានរំលាយ។ ស្ត្រីមេផ្ទះទាំងនេះ តែងតែជួបជុំគ្នាចេញមុខយ៉ាងសកម្មជារៀងរាល់ថ្ងៃសុក្រ ដើម្បីតវ៉ាឱ្យតុលាការទម្លាក់បទចោទចំពោះស្វាមីរបស់ខ្លួនជិត ៣ឆ្នាំមកហើយ។

ស្ត្រីថ្ងៃសុក្រម្នាក់ទៀត គឺអ្នកស្រី **អ៊ុក ចន្ធី** វ័យ ៥៥ឆ្នាំបានរម្លឹកដែរថា គាត់មានអនុស្សាវរីយ៍ជាច្រើនជាមួយអ្នកស្រី **សោម ចន្ធូ** រាប់មិនអស់ក្នុងពេលទាមទារយុត្តិធម៌រយៈពេលជិត ៣ឆ្នាំមកនេះ។ អ្នកស្រីថា ពេលខ្លះមានការរុញច្រានពីអាជ្ញាធរ បណ្ដាលឱ្យមានរបួសស្នាម ក្នុងពេលធ្វើសកម្មភាពម្ដងៗ ប៉ុន្តែអ្នកស្រី **សោម ចន្ធូ** នៅតែ

ប្ដេជ្ញាមកចូលរួមជួបជុំជាមួយស្រ្តីថ្ងៃសុក្រផ្សេងៗ ទៀតមិនដែលខកខានម្ដងណាឡើយ ដោយសង្ឃឹមថានឹងបានជួបជុំស្វាមីឡើងវិញ។

នាថ្ងៃចុងក្រោយនៃជីវិត អ្នកស្រី **សោម ចន្ទ** បានចាប់ដៃជាមួយ អ្នកស្រី **អ៊ុក ចន្ទី** ដោយបង្ហូរទឹកភ្នែកចុះមក ដោយដឹងថា គាត់មិនអាចបន្តដំណើរទាមទារយុត្តិធម៌ជាមួយសមាជិកស្រ្តីថ្ងៃសុក្រផ្សេងៗបានទៀតទេ។

អ្នកស្រីថា៖ «*គ្រាន់តែខ្ញុំទៅដល់ [មន្ទីរពេទ្យ] ភ្លាម គាត់ហុចដៃមកចាប់ដៃខ្ញុំ ហើយខ្ញុំក៏ចាប់ដៃគាត់វិញ ហើយគាត់ក៏ហូរទឹកភ្នែក ខ្ញុំហូរទឹកភ្នែកដូចគ្នា បង្ហាញអារម្មណ៍ក្ដុកក្ដួល គាត់ទទួលដឹងថា គាត់ប្រហែលជាមិនអាច តស៊ូបានទៅមុខទៀត គឺគាត់ក្ដាប់ដៃខ្ញុំយ៉ាងណែន និយាយដល់ចំនុចហ្នឹងខ្ញុំមានអារម្មណ៍ក្ដុកក្ដួល ខ្ញុំទទួលយកអត់បាន*»។

អ្នកស្រី **សោម ចន្ទ** បានរៀបការជាមួយលោក **សុខ ចន្ថា** ក្នុងអំឡុងឆ្នាំ ១៩៨៥។ អ្នកស្រីគឺជាកូនស្រីច្បងក្នុងចំណោមបងប្អូន ៥នាក់ ដែលមានស្រុកកំណើតនៅភូមិ ៥ ឃុំព្រែកខ្សាយ ស្រុកពាមរក៍ ខេត្តព្រៃវែង។

ស្រ្តីថ្ងៃសុក្រម្នាក់ទៀត គឺអ្នកស្រី **កុល សាត** វ័យ ៣៨ឆ្នាំ បានប្រាប់វីអូឌីថា ក្នុងថ្ងៃដែល តុលាការប្រកាសសាលក្រមកាត់ទោសមន្រ្តីគណបក្សសង្គ្រោះជាតិដាក់ពន្ធនាគារ ដែលរួមមានទាំងស្វាមី អ្នកស្រី **អ៊ុក ចន្ទី** ផងនោះគឺ ជាថ្ងៃដែល អ្នកស្រី **អ៊ុក ចន្ទី** ឈឺចាប់បំផុត ដោយបានស្រែកយ៉ាងខ្លាំងៗថា **កម្ពុជាជាសង្គមអយុត្តិធម៌** ដែលបានកាត់ទោសស្វាមីរបស់គាត់ទាំងមិនមានភស្តុតាងច្បាស់លាស់នោះទេ។

អ្នកស្រីថា៖ «*ពេលដែលគាត់នៅមានជីវិត ពេលដែលគាត់ទៅថ្ងៃមួយកម្មវិធីកោរសក់គាត់ដើម្បីថ្វាយសក់ តស៊ូមតិដើម្បីឱ្យគេដោះលែងប្ដី ពួកខ្ញុំក៏ដូចជាអ្នកទោសមនសិកាផ្សេងទៀត  ខ្ញុំចង់ចាំសម្ដីគាត់។ គាត់ថាស្រុកខ្មែរយើងនេះ ជំនាន់ខ្ញុំប៉ុណ្ណឹងទៅ*

*ហើយ! ធ្វើបាបប្ដីខ្ញុំ ចុះជំនាន់ចៅខ្ញុំ ឬចៅទួតខ្ញុំទៅក្រោយៗទៀត តើចៅពួកខ្ញុំឬចៅទួតរបស់ខ្ញុំ តើមានសិទ្ធិសេរីភាពដែរឬក៏អត់?*»។

កាលពីថ្ងៃទី៧ ខែមករា ឆ្នាំ២០២៣ ទណ្ឌិតជិត៣០០នាក់ត្រូវបានបន្ធូរបន្ថយ និងលើកលែងទោស ប៉ុន្តែមិនមានវត្តមានសកម្មជនបក្សប្រឆាំង ឬអ្នកជាប់ឃុំមនសិការផ្សេងៗទៀតនោះទេ។ ជាមួយគ្នានេះ ក្រុមស្ត្រីថ្ងៃសុក្រ បានចាត់ទុកថា នេះគឺជារឿងអយុត្តិធម៌ និងមានការរើសអើងផ្នែកនយោបាយ ដែលមិនមានសកម្មជនបក្សប្រឆាំងណាម្នាក់ត្រូវបានបន្ថយទោស។

លោក **សុខ ចំរើន** វ័យ២៨ឆ្នាំ ដែលត្រូវជាកូនបង្កើតរបស់ អ្នកស្រី **សោម ចន្ធូ** បានឱ្យដឹងថា ក្នុងពេលដែលម្ដាយខ្លួនបានស្លាប់ ក៏មិនមានការអនុញ្ញាតឱ្យឪពុករបស់ខ្លួនបានជួបម្ដាយជាលើកចុងក្រោយនោះដែរ។ លោកបន្ថែមថា នៅពេលឪពុករបស់លោកជាប់ក្នុងពន្ធនាគារ គឺបន្ទុកក្នុងគ្រួសារត្រូវធ្លាក់ទៅលើអ្នកស្រី **សោម ចន្ធូ** ដោយគាត់បាន លក់ចង្រ្កឹត និងកំពឹសចៀនដឹកកង់ជិះលក់តាមផ្ទះនៅស្រុកកំណើត ។

លោក **សុខ ចំរើន** គឺជាកូនទី២ ក្នុងចំណោមបងប្អូន៣នាក់។ លោកប្រាប់ថា ម្ដាយរបស់គាត់បានផុតដង្ហើមក្នុងមន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនព្រះកុសុមៈ(ពេទ្យលោកសង្ឃ)ក្នុងរាជធានីភ្នំពេញ ក្រោយពេលសម្រាកបានត្រឹមរយៈពេល ២ថ្ងៃ។

លោក ចំរើន និយាយថា ម្ដាយរបស់ខ្លួនមានជំងឺប្រចាំកាយ រួមមាន លើសសម្ពាធឈាម ទឹកនោមផ្អែម បណ្ដាលឱ្យគាត់ខ្សោយកម្លាំង និងរួមផ្សំការពិបាកចិត្តក្នុងពេលដែលស្វាមីជាប់ពន្ធនាគាផង ទើបបណ្ដាលឱ្យគាត់ស្លាប់លឿនបែបនេះ។

លោកថា៖ «*ម្ដាយខ្ញុំគាត់ឈឺចិត្តពេក ដែលប្ដីគាត់ការពារជាតិ តស៊ូដើម្បីជាតិ ប៉ុន្តែបែរជាគេ ចោទគាត់ថា ក្បត់ជាតិ ដល់ពេលទៅគាត់ឈឺចិត្តពេកឥឡូវគាត់ស្លាប់បាត់ទៅហើយ*»។

ទោះជាយ៉ាងណា ក្នុងពេលដែល អ្នកស្រី **សោម ចន្ទ** នៅមានជីវិត លោក **សុខ ចំរើន** បានប្រាប់ថា ទោះជាមានជំងឺប្រចាំកាយ ប៉ុន្តែម្ដាយរបស់ខ្លួនតែងតែធ្វើដំណើរទៅរាជធានីភ្នំពេញជានិច្ចដើម្បីចូលរួមតវ៉ាជាមួយស្ត្រីថ្ងៃសុក្រផ្សេងៗទៀត ដោយមានគាត់ជាអ្នកជូនទៅផ្ទាល់។ លោកថា ដោយបារម្ភពីសុខភាពម្ដាយរបស់ខ្លួន លោកក៏មិនចង់ឱ្យម្ដាយចេញមុខតវ៉ាដែរ ប៉ុន្តែគាត់មិនព្រម ដោយនៅតែបន្តចូលរួមជាមួយស្ត្រីថ្ងៃសុក្រផ្សេងៗទៀត ដោយរំពឹងថា តុលាការនឹងដោះលែងស្វាមីរបស់ខ្លួន។

លោកថា៖ *«ចេះតែហាមគាត់ថា ម៉ែឯងសម្រាកសិនទៅ ម៉ែឯង អត់ស្រួលខ្លួនទេ តែគាត់នៅតែទៅចឹង ដើម្បីទៅជួយក្រុមទាំងអស់គ្នា ជួយតវ៉ាស្រែក ដើម្បីប្រាប់ទៅអន្តរជាតិឱ្យគាត់បានដឹង បានឮសុំអន្តរាគមន៍ពីអន្តរជាតិ*»។

លោក ចំរើន បង្ហាញក្ដីស្រណោះចំពោះឪពុករបស់ខ្លួនទាំងមិនបានជួបមុខភរិយាមុនពេលលាចាកលោក ទោះបីជាលោកបានស្នើសុំមន្ត្រីពន្ធនាគារអនុគ្រោះឱ្យឪពុករបស់ខ្លួនបានមកអុជធូបនៅមុខសពអ្នកស្រី **សោម ចន្ទ** ជាលើកចុងក្រោយក៏ដោយ ប៉ុន្តែមិនមានការអនុគ្រោះទេ។

លោកនិយាយថា៖ «*គ្រួសារគេផ្សេងជុំគ្នា គ្រួសារអ្នកស្នេហាជាតិគឺត្រូវបែកបាក់គ្នាទាំងអស់អត់នៅបានជុំគ្នាទេ គាត់ [អាជ្ញាធរ] បំបែកបំបាក់ទាំងអស់*»។

ជំពូកទី២ នៃព្រះរាជក្រឹត្យស្ដីពីការបន្ធូរបន្ថយទោស និងលើកលែងទោស បានលើកឡើងថា ការបន្ធូរបន្ថយទោស និងលើកលែងទោសដល់ទណ្ឌិត ត្រូវធ្វើឡើង

ចំនួន៥ដងក្នុងមួយឆ្នាំ តែត្រូវស្ថិតក្នុងពិធីបុណ្យចំនួន៥ រួមមាន ទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍ ៧មករា, ពិធីបុណ្យចូលឆ្នាំខ្មែរ, ពិធីបុណ្យវិសាខបូជា, ពិធីបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា និងពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក និងសំពះព្រះខែ។

ព្រះរាជក្រឹត្យដដែលបន្តថា ទណ្ឌិតដែលទទួលបានការបន្ធូរបន្ថយទោស លុះត្រាតែអនុវត្តទោសបាន ១\៣ (មួយភាគបី) នៃទោសដាក់ពន្ធនាគារដែលតុលាការបានកំណត់។ ចំពោះទោសដាក់ពន្ធនាគារមួយជីវិត ទណ្ឌិតត្រូវអនុវត្តទោស១០ឆ្នាំជាមុនសិន។ ចំណែកលក្ខខណ្ឌលើកលែងទោសវិញ ទណ្ឌិតត្រូវបានអនុវត្តឱ្យបានចំនួន ២/៣(ពីរភាគបី)នៃទោសសិន។ ចំពោះទណ្ឌិតដែលត្រូវប្រឈមទោសដាក់ពន្ធនាគារអស់មួយជីវិត អាចត្រូវបានលើកលែងទោស ត្រូវអនុវត្តទោសបានយ៉ាងតិច៣០ ឬ២០ឆ្នាំ ក្នុងករណីមានការបន្ធូរបន្ថយទោស។

កាលពីថ្ងៃទី២១ ខែសីហា ឆ្នាំ២០២២ សមត្ថកិច្ចបានផ្ទេរសកម្មជនបក្សប្រឆាំងចំនួន១៩នាក់ ក្នុងចំណោមអ្នកជាប់ឃុំផ្សេងទៀត ចេញពីពន្ធនាគារព្រៃស ទៅកាន់ពន្ធនាគារត្រពាំងថ្លុង ខេត្តត្បូងឃ្មុំ ក្បែរព្រំដែនវៀតណាម ដោយគ្រួសារនិងមេធាវីអះអាងថា សមត្ថកិច្ចមិនបានបញ្ជាក់ពីមូលហេតុច្បាស់លាស់ និងមិនបានជូនដំណឹងដល់ពួកគេឡើយ។

សកម្មជនគណបក្សសង្គ្រោះជាតិដែលត្រូវតុលាការរំលាយកាលពីឆ្នាំ២០១៧ ត្រូវបានថៅក្រមសាលាដំបូងរាជធានីភ្នំពេញ ចោទប្រកាន់ពីបទ «**ញុះញង់ និងរួមគំនិតក្បត់**» ពាក់ព័ន្ធនឹងការគាំទ្រដំណើរវិលត្រលប់មិនបានសម្រេចរបស់លោក សម រង្ស៊ី និងមន្ត្រីបក្សប្រឆាំងផ្សេងទៀត កាលពីថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១៩។

ក្រោយពីមានការកាត់ទោសក្រុមសកម្មជនបក្សប្រឆាំងក្នុងទ្រង់ទ្រាយធំចំនួន៥៣នាក់នេះរួចមក អ្នកជំនាញសិទ្ធិមនុស្សនៅអង្គការសហប្រជាជាតិ កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ បានស្នើទៅរដ្ឋាភិបាលកម្ពុជាឱ្យពិនិត្យឡើងវិញលើករណីនេះ ដោយសម្អាងថា វិធាននោះមិនបានភ្ជាប់កាតព្វកិច្ចនៃការគោរពសិទ្ធិមនុស្សអន្តរជាតិ និងលំហានយោបាយពហុបក្សឡើយ។

ជុំវិញករណីនេះ នាយកផ្នែកតស៊ូមតិនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លោក **សួន យុធ្យា** សង្កេតឃើញថា ការកាត់ទោសមន្ត្រីអតីតគណបក្សសង្គ្រោះជាតិដាក់ពន្ធនាគារនេះ គឺមិនមានភាពយុត្តិធម៌នោះទេ ដោយថា ជារឿងនយោបាយដែលបក្សកាន់អំណាចធ្វើឡើងដើម្បីបង្ក្រាបគូប្រជែងរបស់ខ្លួនដោយប្រើប្រាស់វិធានការច្បាប់តែប៉ុណ្ណោះ។

ពាក់ព័ន្ធនឹងមរណភាពរបស់អ្នកស្រី **សោម ចន្ធូ** លោកថា តុលាការគួរមានការអនុគ្រោះឱ្យលោក **សុខ ចន្ទា** ចេញពីពន្ធនាគារដើម្បីគោរពវិញ្ញាណក្ខន្ធភរិយារបស់ខ្លួនគឺអ្នកស្រី **សោម ចន្ធូ** ផងដែរ។

លោកថា៖ *«ទោះបីជាច្បាប់តឹងរឹងយ៉ាងណាក៏ដោយ ក៏មានករណីលើកលែងមួយ ដែលតុលាការអាចឆន្ទានុសិទ្ធិរបស់គាត់អនុញ្ញាតឱ្យ គ្រួសារចូលរួម បុណ្យសព គ្រួសារគាត់។*

លោកបន្ថែមថា៖ *«ព្រោះមែនទែនទៅ បើសិនជាតុលាការគោរពទៅតាមនិតិវិធី ហើយនិតិវិធីទាំងនោះគោរពទៅតាមច្បាប់ជាតិ ពួកគាត់ក៏មិនចាំបាច់បែបគ្នាអ៊ីចឹងដែរ បើសិនជាច្បាប់យើងគោរពទៅតាម និតិសិទ្ធមនុស្សអន្តរជាតិ ឬក៏សន្ធិសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជា ជារដ្ឋហត្ថលេខី នឹងមិនមានរឿងហ្នឹងកើតឡើងទេ»*។

អ្នកនាំពាក្យក្រសួងមហាផ្ទៃលោក **ខៀវ សុភ័គ** មិនអាចសុំការអត្ថាធិប្បាយបន្ថែមបាន នៅថ្ងៃអង្គារ ដោយទូរសព្ទចូលជាច្រើនដង ប៉ុន្តែលោកបានចុចបិទទូរសព្ទ។

ចំណែក លោក នុត សវនា អ្នកនាំពាក្យអគ្គនាយកដ្ឋានពន្ធនាគារ នៃក្រសួងមហាផ្ទៃមិនអាចអាចសុំការអត្ថាធិប្បាយបន្ថែមបាននៅថ្ងៃអង្គារ ដោយលោកអះអាងថារវល់ប្រជុំ។

យ៉ាងណាក្តី អ្នកនាំពាក្យក្រសួងយុត្តិធម៌លោក **ជិន ម៉ាលីន** បានឆ្លើយតបជាមួយអ្នកសារព័ត៌មាន វីអូឌី តាមប្រព័ន្ធតេលេក្រាមយ៉ាងខ្លីថា ករណីនេះ ជាការសម្រេចរបស់តុលាការ ដូច្នេះ ក្រសួងយុត្តិធម៌មិនមានអ្វីបកស្រាយបន្ថែមទេ។

លោកសរសេរថា៖ *«គាត់អាចធ្វើសំណើទៅកាន់តុលាការ ហើយការសម្រេចគឺនៅលើតុលាការ មិនមែនក្រសួងយុត្តិធម៌អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ»*។

យ៉ាងណាក្តី លោក **សុខ ចំរើន** បាននិយាយថា លោកគ្រោងដាក់សំណើជាផ្លូវការទៅតុលាការដើម្បីអនុញ្ញាតឱ្យឪពុករបស់ខ្លួនបានចេញធ្វើបុណ្យខួប១០០ថ្ងៃ ដែលគ្រោងធ្វើនាពេលខាងមុននេះ។

ទោះជាបែបណាក្តី មុនពេលផុតដង្ហើម លោក **សុខ ចំរើន** បានប្រាប់ថា ម្តាយរបស់ខ្លួន មានបណ្តាំចុងក្រោយជាមួយលោកថា ត្រូវស្រលាញ់បងប្អូន ហើយថាធ្វើជាមនុស្សត្រូវមានឧត្តមគតិស្នេហាជាតិ ដោយមិនត្រូវក្បត់ជាតិដើម្បីបម្រើផលប្រយោជន៍ខ្លួនឯងនោះឡើយ។

លោក សុខ ចំរើន និយាយថា៖ *«ពេលនៅឡើងឡានពេទ្យគាត់ [អ្នកស្រី សោម ចន្ទ] ផ្តាំខ្ញុំថា ម៉ែទៅលែងរួចហើយកូន! គាត់ឱ្យខ្ញុំហ្នឹងតស៊ូទៅមុនទៀត ហើយមើលថែបងប្អូន៣នាក់ហ្នឹង បងប្អូនមានតែ៣នាក់ទេ ហើយគាត់ឱ្យខ្ញុំតស៊ូទៅមុខទៀតមិន*

*បោះបង់ទេ អ្វីដែលគាត់ធ្លាប់ស្រលាញ់ជាតិ ធ្លាប់តស៊ូដើម្បីជាតិយ៉ាងម៉េច គាត់ឱ្យតស៊ូទៅមុខទៀតកុំរាថយ* »៕